**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
លេខៈ ៤៨៥/២២គ.វ.ក-១៩

ថ្ងៃអង្គារ ១១កើតខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២

**រដ្ឋលេខាធិការក្រសួងសុខាភិបាល**
**និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស**

**សូមជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត និងជាប្រធាន**
**អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្តទាំង២៥**

**កម្មវត្ថុ** ៖ ការបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋដែលមិនទាន់បានវ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ (ទាំងដូសទី៣ និងដូសទី៤)។

**យោង** ៖ ប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ដោយផ្ទាល់មក គ.វ.ក-១៩ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅព្រឹកថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ក្រោយចប់ពិធីប្រគល់-ទទួលវ៉ាក់សាំងកូវីសែលដែលជាជំនួយដ៏ថ្លៃថ្លាពីរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋឥណ្ឌា ជូនរដ្ឋាភិបាល និងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ គ.វ.ក-១៩ សូមធ្វើការណែនាំ ជូនដល់ ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត និងជាប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្តទាំង២៥ ដូចខាងក្រោម៖

- ពង្រឹង និងបន្តជំរុញការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ដូសជំរុញ ទាំងដូសទី៣ និងដូសទី៤ ដោយធ្វើយុទ្ធនាការចុះចាក់នៅតាមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមទីវត្តអារាម និងនៅតាមតំបន់កំសាន្តសំខាន់ៗ ក្នុងអំឡុងពេលចូលឆ្នាំប្រពៃណីជាតិខ្មែរ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២។
- អនុវត្តតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គ.វ.ក-១៩ នឹងបញ្ជូនក្រុមគ្រូពេទ្យយុវជនស្ម័គ្រចិត្ត ចុះចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ដូសជំរុញ (ទាំងដូសទី៣ និងដូសទី៤) នៅតាមខ្នងផ្ទះក្នុងភូមិសាស្ត្រនៃខេត្តកំពង់ចាម កំពត ព្រៃវែង កំពង់ឆ្នាំង ត្បូងឃ្មុំ កំពង់ធំ ពោធិ៍សាត់ ស្វាយរៀង ស្ទឹងត្រែង និងក្រចេះ ចាប់ពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២២ ដោយរដ្ឋបាលខេត្ត និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ត្រូវរួមសហការសម្របសម្រួល និងកៀរគរប្រជាពលរដ្ឋ ក្នុងយុទ្ធនាការចុះចាក់នេះឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ។
- ក្រុមគ្រូពេទ្យ នៃក្រសួងការពារជាតិ នឹងធ្វើយុទ្ធនាការចុះចាក់តាមខ្នងផ្ទះប្រជាពលរដ្ឋ និងរោងចក្រ-សហគ្រាសនៃ ភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន (ដូសទី១ និងដូសទី២) និងដូសជំរុញ (ដូសទី៣ និងដូសទី៤) ដោយរដ្ឋបាលរាជធានី-ខេត្ត និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ត្រូវរួមសហការសម្របសម្រួល និងកៀរគរប្រជាពលរដ្ឋ ក្នុងយុទ្ធនាការចុះចាក់នេះឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

- ខេត្តផ្សេងទៀតដែលមិនបានរៀបរាប់ឈ្មោះខាងលើ សូមទទួលខុសត្រូវក្នុងការជំរុញធ្វើយុទ្ធនាការចុះចាក់តាមខ្នងផ្ទះ ដោយប្រើប្រាស់កម្លាំងគ្រូពេទ្យនៅតាមមូលដ្ឋានសុខាភិបាល ឬគ្រូពេទ្យស្ម័គ្រចិត្តនានាដែលមាននៅក្នុងខេត្ត ដោយត្រូវមានផែនការច្បាស់លាស់ និងមានការឯកភាពជាមុនពី គ.វ.ក-១៩ ធ្វើយ៉ាងណាឱ្យវ៉ាក់សាំងកូវីដ-១៩ បានស្រោចស្រពពេញលេញជូនប្រជាជននៃដែនសមត្ថកិច្ចរបស់ខ្លួនទាំងដូសមូលដ្ឋាន និងដូសជំរុញ (ទាំងដូសទី៣ និងដូសទី៤) ជាពិសេសត្រូវយកចិត្តទុកដាក់ចាក់ជូនកម្មករ កម្មការិនី នៅតាមរោងចក្រ និងសហគ្រាសនៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលខេត្តរៀងៗខ្លួន។
- សូមយកចិត្តទុកដាក់ខ្ពស់លើការងារគ្រប់គ្រង និងប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩ ដែលទទួលបានពីឃ្លាំងឱសថកណ្តាលនៃក្រសួងសុខាភិបាល ដោយប្រើប្រាស់ឱ្យអស់ កុំឱ្យសល់ និងកុំឱ្យហួសកាលបរិច្ឆេទនៃសុពលភាពប្រើប្រាស់។
- ការធ្វើយុទ្ធនាការដូចបានណែនាំខាងលើនេះ ត្រូវអនុវត្តការចាក់វ៉ាក់សាំងកូវីដ-១៩ជូនដល់គ្រប់ក្រុមអាយុចាប់ពី៣ឆ្នាំឡើងទៅ ហើយអ្នកដែលដល់វេនចាក់ដូសជំរុញ (ទាំងដូសទី៣ និងដូសទី៤) ក៏ត្រូវផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់ពួកគាត់ សំដៅពង្រឹង និងបង្កើនភាពស៊ាំរបស់បុគ្គល និងសហគមន៍ បានរឹងមាំ ទប់ស្កាត់បានទាន់ពេលវេលាពីការវាយលុកធ្ងន់ធ្ងរនៃវីរុសកូវីដ-១៩ ជាពិសេសពួកបំប្លែងខ្លួនថ្មីៗ ដើម្បីបងប្អូនប្រជាពលរដ្ឋបន្តការរស់នៅជាធម្មតាក្នុងប្រក្រតីភាពថ្មី បានជានិរន្តរ៍តរៀងទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត និងជាប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្តទាំង២៥ ចូលរួមសហការ និងចាត់ចែងអនុវត្តជាបន្ទាន់ឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានដ៏ស្មោះអំពីនាងខ្ញុំ។

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)**

**វេជ្ជ. ឱ្យ-វណ្ណឌីន**

**ចម្លងជូន៖**
-ក្រសួងការពារជាតិ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងអប់រំ យុវជន និងកីឡា
-មន្ទីរសុខាភិបាលរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩